## ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌

លេខ : ១៤១ កសរ.ជស/២៣

# ប្រកាស

# ស្តីពី

# ការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២ នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២៣/៥២០ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃរចនាសម្ព័ន្ធចំណុះបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា
- យោងកំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា លើកទី២ នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣
- យោងតាមតម្រូវការចាំបាច់ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

# **សម្រេច**

**ប្រការ ១.-**

ត្រូវបានកំណត់ឱ្យជ្រើសរើស**សិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២** នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា **ចំនួន ៥០** (ហាសិប) **នាក់** តាមរយៈការប្រឡងប្រជែង ពីក្នុងចំណោមមន្ត្រីរាជការ និងនិស្សិត។

**ប្រការ ២.-**

ការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២ មាន ២ (ពីរ) ដំណាក់កាលៈ

**ដំណាក់កាលទី១ៈ ការប្រឡងប្រជែងលើវិញ្ញាសាសរសេរ** មានចំនួន ៤ (បួន) **មុខវិជ្ជា គឺ:**

- **នីតិព្រហ្មទណ្ឌ** (នីតិព្រហ្មទណ្ឌទូទៅ នីតិព្រហ្មទណ្ឌពិសេស) **និងនីតិវិធីព្រហ្មទណ្ឌ**

| | | |
|---|---|---|
| | រយៈពេល ០៣ ម៉ោង | មេគុណ ២ |
| - **នីតិរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី** | រយៈពេល ០៣ ម៉ោង | មេគុណ ២ |
| - **នីតិការងារ** | រយៈពេល ០១ ម៉ោង ៣០នាទី | មេគុណ ១ |
| - **នីតិពាណិជ្ជកម្ម** | រយៈពេល ០១ ម៉ោង ៣០នាទី | មេគុណ ១ |

ករណីបើបេក្ខជនអវត្តមានក្នុងការប្រឡងប្រជែង ចំពោះមុខវិជ្ជាណាមួយក្នុងចំណោមមុខវិជ្ជាទាំងបួនខាងលើ នឹងត្រូវធ្លាក់ដោយស្វ័យប្រវត្តិ។

ការប្រឡងប្រជែងលើវិញ្ញាសាសរសេរខាងលើនឹងប្រព្រឹត្តទៅនៅ**ថ្ងៃសៅរ៍ ទី១៦ ដល់ថ្ងៃអាទិត្យ ទី១៧ ខែធ្នូ ឆ្នាំ២០២៣**។

**ដំណាក់កាលទី២ៈ ការប្រឡងប្រជែងលើវិញ្ញាសាសួរផ្ទាល់មាត់ មានចំនួន ១ (មួយ) មុខវិជ្ជា គឺ:វប្បធម៌ទូទៅ** (ពាក់ព័ន្ធវិស័យច្បាប់ និងយុត្តិធម៌)។

រយៈពេលសម្រាប់ត្រៀម សួរ និងឆ្លើយសំណួរត្រូវកំណត់ដោយគណៈកម្មការនាយក នៃការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២។

ចំពោះកាលបរិច្ឆេទនៃការប្រឡងប្រជែងវិញ្ញាសាសួរផ្ទាល់មាត់ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា នឹងជូនដំណឹងនៅពេលក្រោយ។

**ប្រការ ៣.-**

លក្ខខណ្ឌនៃការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ត្រូវបានកំណត់ដូចខាងក្រោមៈ

១- បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ជាតិខ្មែរពីកំណើត

២- ត្រូវមានអាយុ ៣៥ (សាមសិបប្រាំ) ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៤០ (សែសិប) ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការគិតមកដល់ថ្ងៃប្រឡង

៣- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រច្បាប់ឡើងទៅ

៤- ត្រូវមានលិខិតថ្កោលទោសចេញពីក្រសួងយុត្តិធម៌បញ្ជាក់ថា មិនធ្លាប់មានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

៥- ត្រូវមានលិខិតបញ្ជាក់សុខភាពចេញដោយពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៦- ត្រូវមានឈ្មោះក្នុងបញ្ជី ប្រកាសស្តីពី ការទទួលស្គាល់បេក្ខជនអនុញ្ញាតឱ្យចូលប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២។

**ប្រការ ៤.-**

ការរៀបចំ បែបបទ និងនីតិវិធីនៃការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២ ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ ៥.-**

សមាសភាពគណៈមេប្រយោគ និងគណៈកម្មការនានា ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់គណៈកម្មការនាយក នៃការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចាត់វិធានការនានា ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និងដំណើរការល្អនៃការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ជំនាន់ទី១២។

**ប្រការ ៦.-**

នាយកខុទ្ទកាល័យ ប្រធានបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា អគ្គលេខាធិការ គ្រប់នាយកសាលាភូមិន្ទវិជ្ជាជីវៈ និងសាលាច្បាប់ នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា និងប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ នៃក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល** :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ កាលប្បវត្តិ